# ការសំភាសន៍របស់លោកពូ កែវ វណ្ណថន

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍ កែវ វណ្ណថន

**<u>ការសង្ខេបប្រវត្តិរបស់លោកពូ កែវ វណ្ណថន</u>**

លោកពូ កែវ វណ្ណថន មានអាយុ56ឆ្នាំ នៅឆ្នាំ2018។លោកពូ កែវ វណ្ណថន មានភេទប្រុសលោកពូ កែវ វណ្ណថន មានទីលំនៅបច្ចុប្បន្ននៅភូមិ 5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ។

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិច ដែរមានឈ្មោះBYUហាសអ៊ុំ ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗអោយពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្តាយនឹងដូនតាចឹងហាសអ៊ុំ ហើយនៅពេលដែរខ្ញុំសំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ ចឹងអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ បាទបានតា

កៈ ចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍អ៊ុំ ខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍អ៊ុំគឺនៅថ្ងៃទី9 ខែ2 ឆ្នាំ2018 ហើយការសំភាសន៍មួយនេះត្រូវបានធ្វើឡើងនៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ ចឹងសំរាប់អ៊ុំមានឈ្មោះពេញ ឈ្មោះអីគេដែរអ៊ុំ?

ខៈ ខ្ញុំឈ្មោះ កែវ វណ្ណថន

កៈ ឈ្មោះ កែវ វណ្ណថន ចុះមានឈ្មោះហៅក្រៅដែរទេអ៊ុំ?

ខៈ អូ៎!ឈ្មោះហៅក្រៅឈ្មោះ វណ្ណថន

កៈ ចុះកាលពីក្មេងធ្លាប់មាននរណាហៅឈ្មោះអ៊ុំអីផ្សេងទៀតទេអ៊ុំ?

ខ៖ មានតានៅពីក្មេងគេហៅឈ្មោះលនចឹងទៅ មានឈ្មោះ3ឈ្មោះកំណើតរបស់ខ្ញុំ
គេប្រើឈ្មោះសព្វថ្ងៃនឹងឈ្មោះលនទៅ
អ្នកដែរហៅខ្ញុំលននឹងមានអ្នកដែរអាយុស្មើរខ្ញុំទេណាស់
នៅពេលដែរគេនៅឆ្ងាយចឹងទៅគេហៅខ្ញុំថាឈ្មោះ វណ្ណថនចឹង

ក៖ ឈ្មោះ វណ្ណថនហោសអ៊ុំ?

ខ៖ តែបើខ្ញុំប្រើនៅក្នុងត្រកូលគ្រួសារវិញ នឹងដាក់ឈ្មោះកែវ វណ្ណថន

ក៖ ចឹងនៅគ្រួសារឈ្មោះកែវ វណ្ណថន?

ខ៖ នឹងដូចនៅអត្តសញ្ញាណប័ណរបស់យើងទេណាស់

ក៖ ចុះពូសព្វថ្ងៃពូអាយុប៉ុន្មានឆ្នាំដែរពូ?

ខ៖ ខ្ញុំអាយុ56ឆ្នាំ

ក៖ ចុះពូកើតនៅថ្ងៃខែឆ្នាំណាដែរពូ?

ខ៖ និយាយអោយចំទៅខ្ញុំកើតនៅថ្ងៃ5 ខែ10ចឹងហាស

ក៖ ចុះឆ្នាំវិញអ៊ុំ?

ខ៖ ខ្ញុំនៅឆ្នាំ1962ឆ្នាំ

ក៖ ពូចងចាំច្បាស់ ចុះពូឆ្នាំច័ន្ទគិតពូឆ្នាំអីគេដែរពូ លក្ខណះថាឆ្នាំជូត ឆ្លូវ ខាល ថោះហាស?

ខ៖ ឆ្នាំខ្មែរហើយនឹងមែន?

ក៖ បាទពូឆ្នាំខ្មែរហាស?

ខ៖ ខ្ញុំឆ្នាំខាល

ក៖ អូ៎!ឆ្នាំខាលហោសពូ ចុះពូកើតនៅស្រុកអី ភូមិអី ខេត្តអីដែរពូ?

ខ៖ នៅកាកាប

ក៖ នៅកាកាបនឹងនៅណាវិញពូ?

ខ៖ កាកាបនៅពោធិ៍ចិនតុងនឹង នៅខ័ណ្ឌដង្កោ
កាលពីមុននឹងប៉ារបស់ខ្ញុំគាត់បានម្តាយរបស់ខ្ញុំនឹងនៅបន្ទាយត្រង់ស្ព័រ

បងរបស់ខ្ញុំពីរនាក់ក៏នៅបន្ទាយត្រង់ស្ព័រ ប្អូនរបស់ខ្ញុំម្នាក់ក៏នៅបន្ទាយត្រង់ស្ព័រ ប៉ុន្តែនៅក្នុងខ័ណ្ឌដង្កោ

ក៖ ប៉ុន្តែភូមិអីគេដែរពូ?

ខ៖ អានឹងបើនិយាយអោយចំទៅ នៅក្នុងបន្ទាយទាហ៊ានតែម្តងនឹង

ក៖ នៅបន្ទាយទាហ៊ាននឹង?

ខ៖ នៅតារាងយន្តហោះនឹងតែម្តងនឹង កាលពីដើមហាស ហើយគ្មានរបងដូចឥឡូវនឹងទេ កាលពីដើមនឹងគ្មានរបងពាត់មកពីណា មានផ្ទះប្រជាជនចឹងទៅ សុទ្ធតែជាទាហ៊ានតាវាអោយទៅនៅនឹង

ក៖ ចឹងពូមានបងប្អូនប៉ុន្មាននាក់ដែរទៅពូ?

ខ៖ បាទបងប្អូនរបស់ខ្ញុំមាន6នាក់

ក៖ ចុះមានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ដែរទេពូ?

ខ៖ ប្រុសមាន5នាក់ ហើយនឹងស្រីមាន1នាក់

ក៖ ចុះពូជាកូនជាទីប៉ុន្មានដែរពូ?

ខ៖ ខ្ញុំជាកូនទី3

ក៖ ចុះពូអាចប្រាប់ឈ្មោះបងប្អូនរបស់ពូបានទេ?

ខ៖ បងរបស់ខ្ញុំនឹងខ្ញុំកើតមកមិនបានទាន់ទេពីព្រោះគាត់បានស្លាប់បាត់ទៅហើយ នឹងមានបងខ្ញុំមួយទៀតនឹងឈ្មោះកែវ វណ្ណ ថុល នឹងបងទី1នឹង

ក៖ ចុះបន្ទាប់មកទៀត?

ខ៖ និយាយអោយចំទៅអ្នកនៅរស់ទេណាស់ បន្ទាប់មកខ្ញុំទី2នឹងឈ្មោះ កែវ វណ្ណថន, កែវ វណ្ណថាធ្វើជាទាហ៊ាន

ក៖ នឹងទី3?

ខ៖ នឹងទី3 មួយទៀត កែវ វណ្ណធី ធ្វើជាមន្រ្តីរាជការ

ក៖ នឹងទី4?

ខ៖ ហើយកែវ វណ្ណ ថាចនឹងក៏ធ្វើជាទាហ៊ានដែរប៉ុន្តែបានស្លាប់បាត់ហើយនឹង

កៈ នឹងពៅគេហោសពូ?

ខៈ បាទពៅគេនឹង

កៈ ចឹងមានន័យថាបងប្អូនស្លាប់អស់2នាក់?

ខៈ ចឹងបងប្អូនយើងមាន6នាក់ ប៉ុន្តែស្លាប់មួយហាស យើងមិនបាច់និយាយទេ ពីព្រោះវានៅតូចហាស ខ្ញុំមិនទាន់និងកើតផងនឹងហាស

កៈ ចុះពូមានអនុស្សាវរីយ៍អីគេចឹងហាស កាលពីពូនៅតូចប៉ុន កូនចៅពូដែរពូគិតថាធ្លាប់លេងអីជាមួយគ្នាហាសពូ?

ខៈ បាទខ្ញុំនៅចងចាំដែរ?

កៈ មានអីគេខ្លះដែរពូ?

ខៈ ពីព្រោះកាលពីមុនខ្ញុំនៅរៀនអីទេ កាលពីខ្ញុំនៅតូចៗហាស កាលពីពេលណុងជំនាន់លុណនុល ហើយខ្ញុំក៏ជំលាសចេញពីបន្ទាយឆេះទៅ ខ្ញុំក៏ទៅនៅជ្រោយចង្វារហោស

កៈ អូ៎!នៅឆ្ងាយដែរពូ?

ខៈ ខ្ញុំទៅនៅឆ្នាំ1973 ហើយក៏បន្ទាយឆេះបានបាក់ស្ពានជ្រោយចង្វារនឹង ហើយក៏ខ្ញុំនៅណុងម្តាយឪពុករបស់ខ្ញុំធ្វើទាហ៊ាននៅណុងនៅដេអិន ហើយនៅក្នុងឆ្នាំ1975ខ្ញុំបានជំលាសពី ជ្រោយចង្វារទៅនៅខេត្តព្រៃវែងទៅ

កៈ អូ៎!បាទពូម៉េចទៀតទៅពូ?

ខៈ ខ្ញុំទៅនៅព្រៃវែងស្រុកកំណើតប៉ារបស់ខ្ញុំទៅ ប៉ុន្តែមិនដែរបានជួបគាត់ទេ ខ្ញុំក៏ចេញទៅរស់នៅរហូតដល់សព្វថ្ងៃនឹង តាំងពីឆ្នាំ1975-1977នឹងខ្ញុំត្រូវរបួស

កៈ ម៉េចបានពូត្រូវរបួសចឹង?

ខៈ របួសនឹងនិយាយអោយចំទៅ ខ្ញុំមិនមែនជាអ្នកទាហ៊ានអីទេ ខ្ញុំនៅកុមារហាស់ណាស់

កៈ ចឹងម៉េចបានត្រូវរបួសចឹងពូ?

ខៈ ខ្ញុំនៅកុមារដល់ពេលចឹងខ្ញុំទៅឃ្វាលគោ ចឹងខ្ញុំមានដឹងថាគ្រាប់បែកពលពតវើសមកដាក់នៅក្រោម ដើមឈើ នឹងដើមព្រៃអីណា ខ្ញុំម៉េចដឹងទៅ ដល់ពេលចឹងខ្ញុំទៅអង្គុយនៅក្រោមដើមចារ ហើយក៏មិនដឹងថាមានគ្រាប់បែកដែរ

កៈ ចុះម៉េចទៅពូ?

ខៈ ហើយខ្ញុំបានលូកដៃទៅនៅខាងឆ្វេងដៃនឹង
ហើយកាន់ដៃឆ្វេងគ្រាប់បែកគេហៅថាគ្រាប់បែកស្មីទេនេះ

កៈ គ្រាប់បែកដៃហោសពូ?

ខៈ គ្រាប់បែកអាជំនាន់បារាំងហោស អានឹងវាខ្លាំងហាសណាស់ ដូចថាគ្រាន់តែកាន់ដៃនឹង

កៈ នឹងលក្ខណៈថាគេះហើយគប់តែម្ដងនឹងហោសពូ?

ខៈ នឹងហើយគ្រាន់តែគេះនឹង ចុះខ្ញុំមានដឹងថាគ្រាប់ណា ពីព្រោះប្រឡាក់សិទ្ធិតែដីនឹង
ខ្ញុំស្មានតែដីក្មេងលើកលេងក៏យកមកកាន់ធ្វើដូចបូលចឹងហាស
ដូចបូលដែរយើងបោះចឹងហាសណាស់

កៈ អូ៎!បាទពូចឹង?

ខៈ ហើយខ្ញុំក៏កាន់ទ្រចឹងទៅ មានកាច់ណា គ្រាន់តែកាន់មិនកាច់ផងវាផ្ទុះ
ខ្ញុំបានសន្លប់ទៅគេសែងខ្ញុំទៅពេទ្យ នៅជំនាន់ពលពត

កៈ ប៉ុន្តែពូត្រូវអីគេខ្លះដែរទៅ?

ខៈ ខ្ញុំត្រូវពីនឹងធ្លាយមកដល់នេះ

កៈ ប៉ុន្តែមិនអីទេហោសពូ?

ខៈ បាក់ធ្មេញ បាក់អីហើយនឹង

កៈ ប៉ុន្តែពូឥឡូវនឹងមិនអីទេ ពូឥឡូវនឹងល្អជាធម្មតាទេ?

ខៈ បាទល្អជាដែរនឹង

កៈ គេវះមែនពូ?

ខៈ អត់វះទេ គេមានវះមកពីណា

កៈ ចុះធ្វើម៉េចបានពូស្អាតដូចដើមចឹងហាសពូ
ខៈ ពំបែងនឹងសព្វថ្ងៃនឹង នៅនឹងមុខដែរនឹង ចុះក្មួយឯងគិតមើលត្រូវពីនឹងទេណាស់
គេវះធ្លាយមកដល់ត្រចៀកទៀតនឹងហាស

កៈ អូ៎!បាទឃើញហើយពូ ប៉ុន្តែបើពូមិនប្រាប់គ្មានរណាគេដឹងថាពូកើតអីទេនឹង?

ខៈ ត្រូវហើយនឹង

កៈ ពូស្អាតតែម្ដងនឹងហាស?

ខៈ គេគគ្មានទៅដឹងទេ ប៉ុន្តែគ្រាន់តែថាយើងត្រូវហើយណាស់ ប៉ុន្តែគ្រាន់តែខ្ញុំពិការដែរ ប៉ុន្តែពិការក្នុងរបបពលពតហាស

កៈ បាទត្រូវហើយពូ?

ខៈ គេហៅថាអាគប់ម៉ាៗពលពតហាស ចឹងវានៅតូចដែរ នៅប្រហែលជាជាងដប់ឆ្នាំដែរនឹង ប្រហែលជា12-13ឆ្នាំនឹង ចុះក្មួយឯងគិតមើលៗថាឥឡូវនឹងយើងមកនៅនេះជាង39ឆ្នាំហើយមែនទេ

កៈ បាទត្រូវហើយពូ

ខៈ នៅជាង39ឆ្នាំហើយ ខ្ញុំមកនៅនឹងជាង15-16ឆ្នាំហើយនឹងកាលណុងខ្ញុំនៅតូចៗ ចុះឪពុកម្ដាយនៅគ្រិនៗហោស គ្មានដឹងស្អីៗទេ មិនមែនដូចក្មេងឥឡូវទេ និយាយអោយចំតែម្ដងនឹង

កៈ បាទត្រូវពូ

ខៈ ចុះជំនាន់អាយុ15-16ឆ្នាំនឹងគ្មានដឹងស្អីៗទេនឹងហាស គ្មានថាចេះស្រលាញ់ស្រី ស្រលាញ់អីយ៉ាងម៉េចទេនឹងហាស

កៈ បាទកាលជំនាន់ណុងមិនចេះស្រលាញ់ស្រីទេពូ?

ខៈ នឹងហើយក្មេងឥឡូវនឹងតែអាយុ10ឆ្នាំវាចេះដឹងថានរណាគេស្រលាញ់ហើយនឹង ហើយខ្ញុំគ្មានដឹងស្អីទេនោះ កាលជំនាន់ណុងដូចថាខ្ញុំពិការប៉ុន្តែដូចជាមិនពិការទេ ខ្ញុំអាចធ្វើការងារបានប៉ុន្តែគ្រាន់តែថាភ្នែករបស់ខ្ញុំនឹងត្រូវពិការដែរ

កៈ ប៉ុន្តែពូឥឡូវនឹងមានអារម្មណ៍ថាភ្នែករបស់ពូនឹងដូចជាអន់មួយចំហើងណាពូ?

ខៈ បាទមើលមិនឃើញតែម្ដងនឹង

កៈ ចឹងពូមើលបានឃើញតែមួយចំហៀងខាងឆ្វេងទេណាពូ?

ខៈ បាទមើលឃើញតែមួយចំហៀងខាងឆ្វេងនឹង បើនិយាយពីខាងនេះមើលមិនឃើញសុទ្ធ

កៈ ដោយសារតែពូត្រូវខាងស្ដាំមែនទេពូ?

ខ៖  នឹងហើយនិយាយអោយចំទៅមើលទៅឃើញតែស្រម៉ោលៗសុទ្ធនឹង ឃើញស្រម៉ោលដូចយប់ចឹងហាស បើនរណាគេចង់ចង្អុលអីយើងមើលមិនឃើញទេ ដោយសារតែយើងដាក់ភ្នែកពីចឹងនរណាគេមិនដឹងថាយើងដាក់ភ្នែកមាំទាំហើយណាស់

ក៖  ចឹងហោសពូ?

ខ៖  ប៉ុន្តែភ្នែករបស់ខ្ញុំនឹងពិការ

ក៖  និយាយមែនបើពូមិនប្រាប់យើងមើលមិនដឹងទេ និយាយរួចពូដូចជាមនុស្សធម្មតាតែម្តងនឹង សូម្បីតែ

ខ៖  នឹងហើយដូចមនុស្សធម្មតាចឹង

ក៖  សូម្បីតែខាងមុខរបស់ពូ ក៏អត់មាននរណាគេដឹងដែរ?

ខ៖  គ្មាននរណាដឹងទេ ចុះយើងគិតមើល ខ្ញុំត្រូវរបួសក្នុងឆ្នាំ1977 រហូតមកដល់ឥឡូវនឹងមិនមែនតិចឆ្នាំទេណាស់

ក៖  ជិត40ឆ្នាំហើយនឹង?

ខ៖  វាជាងប្រហែលនឹង

ក៖  វាជិត41ឆ្នាំហើយ

ខ៖  តាំងពីរបួសល្មមនឹងជាសះអស់ហើយនឹង គ្រាន់តែថាត្រចៀកមួយចំហៀងវាហឹង

ក៖  ត្រចៀកហឹងទៀត?

ខ៖  ចុះយើងពីនឹងទៅវាធ្លាយត្រចៀកហោស យើងបែកក្រដាសត្រចៀកហោស ចុះយើងគិតមើលបែកក្រដាសត្រចៀកហោស អ្នកណាដែរដើរជួបខ្ញុំហៅក៏ដោយ ទាល់តែខ្ញុំក្រលែកមើលចំបានដឹង

ក៖  អ្ហូ!ចឹងមានន័យថាទាល់តែពូនឹង?

ខ៖  បើហៅនឹងសរុបមកទាំងអស់នឹង ចុះក្មួយឯងគិតមើលមនុស្សយើងមានត្រចៀកពីរបើហៅទៅមិនលឺសងខាងមែនអត់?

ក៖  បាទត្រូវហើយពូ

ខ៖ មានឆ្វេងស្តាំ ចុះបើខ្ញុំហៅទៅសរុបចូលមកទាំងអស់នឹងហាស ដល់ពេលដែរមានរុណាតែមួយចឹងទៅ នរណាហៅទៅខាងណាក៏ចូលតែមួយដែរនឹង ដល់ពេលដែរគេសួរទៅ មិនសូវដឹងទេ ចុះបើទៅចុះផ្លូវតែមួយហើយនឹង

ក៖ ចឹងមានន័យថាពូឥឡូវនឹងពូថ្លង់មួយចំហៀង ហើយពិការភ្នែកមួយចំហៀង?

ខ៖ នឹងហើយ

ក៖ ចុះពូគិតថា កាលពីក្មេងៗហាស តើពូធ្លាប់លេងអីជាមួយបងប្អូនរបស់ពូទេ ដែរពូចូលចិត្តលេងហាស ដូចលក្ខណះថាលេងចុយ?
ខ៖ នឹងអាចលេងបានតា អានឹងយើងនិយាយអោយចំថាចឹងក៏បានដែរ ខ្ញុំនៅក្មេងៗ កាលនៅកុមារនឹងខ្ញុំចូលចិត្តតែលេងហ៊ឹង

ក៖ លេងហ៊ឹងហោសពូ អាវៃកូនហ៊ឹងនឹងហោសពូ?

ខ៖ នឹងហើយវៃកូនហ៊ឹងនឹងហាស ដូចថាហ៊ឹងខ្វាក់ចឹងហាសណាស់ នឹងហ៊ឹងចោល មានស្គាល់ហ៊ឹងចោលទេ?

ក៖ ស្គាល់ពូ

ខ៖ នឹងហើតខ្ញុំលេងហ៊ឹងខ្វាក់ នឹងហ៊ឹងចោលនឹង ប៉ុន្តែបើខ្ញុំលេងហ៊ឹងនឹងគ្មាននរណាគេហ៊ានលេងជាមួយខ្ញុំទេ

ក៖ ដោយសារតែពូពូកែលេងមែនទេ?

ខ៖ នឹងហើយពូកែលេងនឹង

ក៖ អាលក្ខណះថាគេវៃម្តងនឹងអោយស៊ីចតែម្តងនឹងហោសពូ?

ខ៖ បាទៗនឹងហើយ ហើយលេងគប់វង់ក៏គ្មាននរណាគេហ៊ានលេងជាមួយខ្ញុំដែរនឹង ប៉ុន្តែខ្ញុំគប់ត្រង់ប៉ុន្តែពេលដែរបោះនោះបោះអត់កើត

ក៖ ពូអត់ចេះបោះហោសពូ?

ខ៖ បាទអត់ចេះបោះទេវាម្យ៉ាងទេ

ក៖ ប៉ុន្តែពូចូលចិត្តលេងឡឹកបាយឡជាមួយបងប្អូនរបស់ពូទេ?

ខ៖ ប៉ុន្តែបើបាល់ទាត់ខ្ញុំលេងតា

ក៖ ប៉ុន្តែឡឹកបាយឡអីពូចូលចិត្តលេងទេ?

ខ៖  និយាយពីឡឹកបាយឡនឹង ខ្ញុំគំរលេងណាស់ឡឹកបាយឡនឹងហាស កាលពីនៅក្មេងខ្ញុំច្រើនតែលេងបាល់បោះចូលឡហោស ធ្លាប់ស្គាល់ទេ

ក៖  បាទស្គាល់តាពូ

ខ៖  នឹងហើយ លេងល្បែងបោះបាល់ចូលឡនឹង ប៉ុន្តែដូចបាល់តូច ដូចប៉ូលចឹងហាស បោះចូលឡនឹងហាស មានលេខ1 លេខ2 លេខ3 បើបោះចូលឡលេខណាចឹង គេដេញគប់ហើយ យើងត្រូវរត់ បើគប់មិនត្រូវគេដាក់បាត់ដៃអោយយើងគប់

ក៖  អូ៎!ខ្ញុំធ្លាប់លេងតាពូ

ខ៖  អានឹងៗខ្ញុំធ្លាប់លេងអានឹង ក្រៅពីនឹងដូចថាល្បែងអីៗនឹងខ្ញុំអត់ចេះទេ ហើយបើក្មេងខ្ញុំលេងបាញ់ឃ្លីនឹង អានឹងលេងបាញ់ឃ្លីហាសណាស់

ក៖  អូ៎!បាញ់ឃ្លីហោសពូ?

ខ៖  នឹងហើយអានឹងក៏លេងមិនដែរចាញ់គេដែរនឹង

ក៖  អូ៎!បាញ់ឃ្លីពូពូកែលេងណាពូ?

ខ៖  នឹងមិនបាច់និយាយទេ ក៏លេងមិនចាញ់គេទេ មានតែប៉ុណ្ណឹងក្រៅពីនឹងមិនដែរបានលេងអីទេនឹងហាស បើថាល្បែងមួយទៀតនឹងខ្ញុំលេងជល់ត្រីគ្រឹម

ក៖  អូ៎!ពូជល់ត្រីគ្រឹមដែរហោសពូ?

ខ៖  បាទខ្ញុំអ្នកលេងត្រីគ្រឹមហើយនឹងលេងមាន់ ប៉ុន្តែសម័យនេះភាគច្រើនគេលេងជល់មាន់ដាក់លុយ ដាក់កាក់ ហើយគេចាប់ហាសណាស់

ក៖  បាទត្រូវហើយពូ

ខ៖  សំរាប់ខ្ញុំជាអ្នកថៃមាន់របស់ខ្ញុំអោយស្អាតចឹងទៅ ដើម្បីអោយជល់អោយឈ្នះគេចឹងហាស ហើយបង្រៀនវាអោយចេះលោត នឹងចេះគេចចឹងហាសណាស់

ក៖  បាទពូ ត្រូវហើយនឹងពូ

ខ៖  ដូចបង្រៀនអោយវា ដូចវៃបុកចឹងហាស

ក៖  ចុះពូគិតថាបងប្អូនរបស់ពូសព្វថ្ងៃនៅណាដែរពូ?

ខ៖ បងរបស់ខ្ញុំបង្អើតនឹង ធ្វើការជាមន្ត្រីរាជការ

ក៖ ប៉ុន្តែនៅភ្នំពេញនឹងទេហោសពូ?

ខ៖ ទេនៅបរសៃតហោស

ក៖ បរសៃតនឹងនៅណាដែរពូ?

ខ៖ បរសៃតនៅខេត្តកំពង់ស្ពឺ

ក៖ នៅខេត្តកំពង់ស្ពឺហោស ចុះប្អូនរបស់ពូគាត់ធ្វើអីគេដែរពូ?

ខ៖ ប្អូនបន្ទាប់របស់ខ្ញុំនឹង ខ្ញុំទី2 បន្ទាប់ខ្ញុំនឹងធ្វើជាទាហ៊ាន

ក៖ ប៉ុន្តែធ្វើនៅណាដែរពូ?

ខ៖ ធ្វើនៅបុរីសោមនោរម្យ

ក៖ នៅខេត្តកំពង់ស្ពឺដែរ?

ខ៖ នៅពោធិ៍ចិនតុង នៅហួសពោធិ៍ចិនតុងទៀតហោស ទៅបន្តិចទៅ
គេហៅថាវត្តជំពូវនៃហោស?

ក៖ នឹងនៅវត្តជំពូវនៃហោសពូ?

ខ៖ ហួសអាយើងផ្លូវទៅបាត់ដំបងចឹងអី វាមានធ្វើច្រើនចឹងខ្ញុំចង់ភ្លេចដែរហើយ
ប្អូនរបស់ខ្ញុំធ្វើទាហ៊ានខាងមីង

ក៖ ផ្នែកស៊ីម៉ាក់នឹងហោសពូ?

ខ៖ នឹងហើយទៅប្រទេសក្រៅ

ក៖ ចុះប្អូនរបស់ពូផ្សេងទៀត?

ខ៖ ប្អូនរបស់ខ្ញុំនឹងប្អូនស្រី ប៉ុន្តែគេទៅធ្វើការងារនៅមន្ត្រីរាជការនឹង ប៉ុន្តែខាងអភិវឌ្ឍន៍

ក៖ បាទពូ ចុះបងប្អូនរបស់ពូសុទ្ធតែមានគ្រួសារអស់ហើយមែនទេពូ?

ខ៖ អ្ហ៎!គេសុទ្ធតែចាស់ៗអស់ហើយនឹងហាស
បើអាយុពៅគេនឹងអាយុ50ឆ្នាំហើយនឹងគិតមើលទៅ ម៉េចបានថាមិនមានម៉េចនឹងកើត

ក៖ ចឹងហោសពូ?

ខ៖ នឹងហើយសូម្បីតែប្អូនរបស់ពៅរបស់ខ្ញុំនឹងចាស់ដែរហើយនឹងហាស

កៈ  បាទពូ ចុះឪពុករបស់ពូមានឈ្មោះអីគេដែរពូ?

ខៈ  គាត់ឈ្មោះ កែវ សារិន

កៈ  ចុះគាត់អាយុប៉ុន្មានដែរពូចងចាំទេ?

ខៈ  អ៊ូ!ខ្ញុំអត់ចាំទេ ខ្ញុំដឹងតែឆ្នាំចរជំនាន់សម្ដេចនឹង អាយុប្រហែលសម្ដេចតានឹង

កៈ  ចឹងមានន័យថាគាត់កើតនៅឆ្នាំ1920ជាងណោះពូ?

ខៈ  បាទពីព្រោះឆ្នាំចរជំនាន់សម្ដេចនឹងហាស

កៈ  ប៉ុន្តែមកដល់ឥឡូវនឹងគាត់អាយុស្គរគ្មានឹងហាស

ខៈ  គាត់សុគត់ក្នុងឆ្នាំនឹង

កៈ  គាត់អាយុ92ឆ្នាំណតាពេលដែរគាត់សុគត់នឹង?

ខៈ  គាត់សុគត់អាយុ92ឆ្នាំ បាទឥឡូវនឹងគិតមើលប៉ុន្មានឆ្នាំហើយនឹង

កៈ  គាត់សុគត់ឆ្នាំ1992នឹងដូចជាឆ្នាំ2010ហីពូ?

ខៈ  ខ្ញុំអត់បានចាំដែរនឹង

កៈ  ឥឡូវនឹងឆ្នាំ2018ចឹងគាត់អត់ដល់100ឆ្នាំ គេគាត់នៅជិតដល់100ឆ្នាំហើយពូ?

ខៈ  បាទក្បែរ ដូចថាអាយុ98-99ឆ្នាំអីចឹងហាសណាស់ ប៉ារបស់ខ្ញុំនឹងប្រហែលគ្នា បើម្ដាយរបស់ខ្ញុំវិញបងប៉ារបស់ខ្ញុំវិញ

កៈ  ម្ដាយរបស់ពូហោស?

ខៈ  បាទឆ្នាំមមែ

កៈ  គាំត់ឆ្នាំមមែ ប៉ុន្តែគាត់មានឈ្មោះអីគេដែរពូ?

ខៈ  គាត់ឈ្មោះណុក សែន គាត់នៅខេត្តតាកែវហោស

កៈ  ចុះឪពុករបស់ពូគាត់នៅណាដែរ?

ខៈ  ប៉ារបស់ខ្ញុំគាត់នៅខេត្តព្រៃវែង

កៈ  ចុះឪពុករបស់ពូកាលពីគាត់នៅរស់គាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរ?

ខៈ  គាត់ធ្វើជាទាហ៊ានដែរ

កៈ  គាត់ធ្វើជាទាហ៊ានហោសពូ?

ខៈ  បាទនៅឆ្នាំលុណនុលបែកគាត់នៅឆ្នាំ1975នឹងបែកគាត់មិនដឹងថាគាត់ស្លាប់រស់ទេនឹង

កៈ  ប៉ុន្តែគាត់កាចរឺមួយក៏ស្លូតដែរពូ?

ខៈ  ប៉ារបស់ខ្ញុំគាត់ស្លូតណាស់

កៈ  គាត់ស្លូតហោសពូ ចុះម្តាយរបស់ពូគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរពូ?

ខៈ  ក្នុងជីវិតរបស់គាត់ លក់ឥវ៉ាន់ចាប់ហួយ

កៈ  គាត់លក់ឥវ៉ាន់ចាប់ហួយណាពូ?

ខៈ  គាត់លក់ចាប់ហួយ នឹងដូចជាមានប៊ីចេង ស្ករ ទឹកត្រី មាននុំអីចឹងហាសណាស់

កៈ  លក្ខណះថាគ្រឿងទេសមួយសពូនឹងហោសពូ?

ខៈ  នឹងហើយ ប៉ុន្តែមិនមែនដូចគេលក់ឥឡូវនឹងលក់ធំៗទេណាស់

កៈ  បាទត្រូវហើយពូ?

ខៈ  ចុះកាលពីជំនាន់ណុងដូចថាគ្រឿងម្ហូបស្លអីចឹង

កៈ  បាទពូ ចុះម្តាយរបស់ពូគាតកាចរឺមួយក៏ស្លូតដែរពូ?

ខៈ  ម្តាយរបស់ខ្ញុំគាត់កាច

កៈ  អ៊ូ!កាចហោសពូ?

ខៈ  បើនិយាយកាច វាកាចហើយ ប៉ុន្តែប៉ារបស់ខ្ញុំនឹងគាត់ស្លូតទេ

កៈ  ចុះពូមានចងចាំសាច់រឿងអីដែរពូគិតថាចង់ជាមួយឪពុកម្តាយរបស់ពូទេ
កាលពីពូនៅជាមួយពួកគាត់ហាស ពូមានចងចាំសាច់រឿងថាពូមានអនុស្សាវរីយ៍អី
ដូចជាដើរលេងអី នឹងទៅស្រែអីជាមួយគ្នាចឹងហាសពូ?

ខៈ  បាទៗៗពីព្រោះប៉ារបស់ខ្ញុំនឹងនិយាយអោយចំទៅគាត់
ជិះឡានបើកមកដល់ផ្ទះហើយនាំកូនចៅដើរលេងហើយនឹង

កៈ  ល្អតាពូគាត់បាននាំកូនចៅដើរលេង?

ខៈ  ប៉ុន្តែគាត់មិនសូវបានដើរទៅណាទេ គាត់ជាអ្នកហូបស្រាប៉ុន្តែគាត់ហូបស្លូតនឹង
កូនចៅចង់ទាត់ធាក់ ជិះក្បាលគាត់ក៏គាត់មិននិយាយអីដែរ

កៈ  អូ៎!គាត់ស្លូតណាពូ?

ខៈ  គាត់ស្លូតណាស់ ប៉ុន្តែបើម្តាយវិញមិនបាច់និយាយទេ អោយតែគាត់ដេកហើយ គ្រាន់តែដើរអង្អើរគ្រែក៏គាត់វៃដែរ

កៈ  អូ៎!ចឹងគាត់កាចណាស់?

ខៈ  គាត់កាចណាស់ម្តាយរបស់ខ្ញុំនឹង

កៈ  បាទពូ ចុះយាយតាខាងម្តាយពូមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ  ខាងម្តាយរបស់ខ្ញុំនឹង បើនិយាយអោយចំទៅបងប្អូនរបស់គាត់ ខ្ញុំមិនសូវចាំដែរពីព្រោះអីខ្ញុំតូចៗៗនឹង តែខ្ញុំទាន់បងប្អូនរបស់គាត់មាន6នាក់ ប៉ុន្តែស្លាប់អស់ហើយនៅសល់តែ2នាក់ទេ

កៈ  ចង់និយាយថាយាយតាខាងម្តាយហាសពូមានស្គាល់ឈ្មោះដែរទេ?

ខៈ  អូ៎!ខ្ញុំអត់ស្គាល់ឈ្មោះគាត់ទេ បើខ្ញុំកើតមិនទាន់គាត់ផងនឹង ម្តាយរបស់ខ្ញុំប្រាប់ដែរប៉ុន្តែខ្ញុំមិនចងចាំទេនឹង

កៈ  ចុះយាយតាខាងឪពុកពូមានចងចាំទេ?

ខៈ  បាទនឹងខ្ញុំចាំ

កៈ  ចុះគាត់មានឈ្មោះអីគេដែរពូ?

ខៈ  តារបស់ខ្ញុំឈ្មោះអឹម ម៉ុល

កៈ  ចុះយាយវិញពូ?

ខៈ  យាយឈ្មោះយាយអឹម ខាងតាឈ្មោះម៉ុល ចុះគាត់នៅខេត្តព្រៃវែង ប៉ុន្តែយើងចេះតែទៅហើយនឹងហាស

កៈ  ចុះឪពុករបស់ពូនិយាយតែបន្តិចនឹងពូមិនចាំតែម្តងនឹងហាស?

ខៈ  បាទដោយសារមានជេត្តដីនឹង ហើយបងប្អូនរបស់ខ្ញុំនៅប្រទេសក្រៅទៅគេហៅចឹងហាស

កៈ  ចុះឪពុកម្តាយរបស់ពូធ្លាប់ប្រាប់ពីប្រវត្តិទៅពូទេ ថាយាយតាគាត់មានធ្លាប់ធ្វើអីគេខ្លះដែរនឹង កាលពីគាត់បានម្តាយឪពុកមកចឹងហាស?

ខៈ  គាត់និយាយគ្រាន់តែថា ហីពីដើមប៉ារបស់ខ្ញុំប្រាប់ទៅខាងតារបស់ខ្ញុំគាត់ធ្វើស្មៀន

កៈ  គាត់ជាស្មៀនណាពូ?

ខៈ  បាទ!តាបង្កើតនឹងជាស្មៀន ដល់ពេលដែរគាត់ធ្វើជាស្មៀនចឹងទៅ
កូនចៅរបស់គាត់មិនដែរបានធ្វើជាស្រែចំការអីដែរ
និយាយទៅគាត់ជាអ្នកស្រណុកហាសណាស់យាយរបស់ខ្ញុំ
តារបស់ខ្ញុំស្រែក៏គាត់មិនដែរធ្វើដែរ

កៈ  អូ្!គាត់អត់ដែរធ្វើអីទេ?

ខៈ  គាត់មិនដែរធ្វើអីទេ ចុះគាត់ធ្វើស្មៀននៅជំនាន់សម្តេចតាហើយ
យើងដឹងស្រាប់ហើយនឹង

កៈ  ចុះពូមកនៅទីក្រុងភ្នំពេញនឹងយូរនៅពូ?

ខៈ  ខ្ញុំមកនៅតាំងពីឆ្នាំ1979

កៈ  តាំងពីឆ្នាំ1979 រហូតមកដល់ឥឡូវនឹងប្រហែលជាអស់38ឆ្នាំទៅ39ឆ្នាំហើយណាពូ?

ខៈ  នឹងហើយប៉ុណ្ណឹង គ្រាន់តែថាចូល39ឆ្នាំ ចង់និយាយថាបានបែក3ថ្ងៃនឹង
ខ្ញុំបានមកដល់ភ្នំពេញតែម្តង

កៈ  អូ្!ចឹងហោសពូ?

ខៈ  បែក3ថ្ងៃយើងមិន7មករា

កៈ  បាទៗៗពូត្រូវហើយនឹង

ខៈ
បែក7មករាគ្រាន់តែប្រកាសថាគេវៃបែកហើយអស់រយះពេល3ថ្ងៃនឹងខ្ញុំក៏បានមកដល់ទីក្រុងភ្នំពេញតែម្តងនឹង

កៈ  បាទពូ! ចុះពូមានបងប្អូនណា
រឺមួយក៏សាច់ញ្ញាតិណាមួយដែរទៅរស់នៅក្រៅប្រទេសទេពូ?

ខៈ  បាទមានបងប្អូននៅប្រទេសក្រៅច្រើនណាស់

កៈ  នរណាគេដែរពូ ពូអាចរៀបរាបប្រាប់បានទេ?

ខៈ  ខ្ញុំនិយាយអោយចំទៅថាឈាម មានតែមួយទេកូនរបស់អ៊ុំខ្ញុំបង្កើតនឹង
កូនរបស់អ៊ុំខ្ញុំបង្កើតនឹងនិយាយពីបងប៉ារបស់ខ្ញុំទេណាស់

កៈ បាទពូយ៉ាងម៉េចទៅពូ?

ខៈ បងប៉ារបស់ខ្ញុំបង្កើតគ្រាន់តែថាកូនត្រូវជាក្មួយប៉ារបស់ខ្ញុំបង្កើត ហើយខ្ញុំត្រូវជាជីដូនមួយបង្កើតនឹង នៅប្រទេសក្រៅបើនិយាយអោយចំទៅជាង មានជាងជិត10នាក់ដែរ

កៈ ប៉ុន្តែគាត់ទៅនៅណាខ្លះដែរទៅពូ?

ខៈ គាត់ទៅនៅអាមេរិច ខ្ញុំមិនសូវស្គាល់ដែរពីព្រោះអីគាត់មិនដែរនិយាយប្រាប់ខ្ញុំទេ

កៈ ចឹងពួកគាត់ទៅនៅអាមេរិចទាំងអស់តែម្តងនឹង?

ខៈ បាទទៅនៅអាមេរិចទាំងអស់នឹង

កៈ អូ៎!ឡូយតែម្តងនឹងចឹង?

ខៈ មាននៅប្រទេសបារាំងមួយដែរ អាមួយនឹងត្រូវជាបងខែខ្ញុំទេ ប៉ុន្តែឆ្នាំស្គរគ្នានឹង ហៅគ្នាអាទៅ នឹងហៅអាមកដែរនឹង

កៈ ប៉ុន្តែឥឡូវនឹងគាត់នៅតែនៅទាក់ទងពូដែរ?

ខៈ ឥឡូវនឹងនៅប្រទេសបារាំងនឹងក៏ខ្ញុំមិនដែរបានលុយកាក់ដែរ ពីព្រោះបងប្អូនរបស់ខ្ញុំគេចិត្តបាន បើនិយាយអោយចំទៅ គេពីដើមនឹងគេហៅបងទីមួយ នឹងបងទីពីរចឹងហាស គេមិនអោយដឹងឈ្មោះចឹងហាសណាស់ខ្លាចអ្នកដំទៃ

កៈ អូ៎!ចឹងហោសពូ?

ខៈ បងស្រីទីមួយមានឈ្មោះថា បងណោន នៅប្រទេសអាមេរិចណោះ

កៈ ប៉ុន្តែពួកគាត់ធ្វើអីគេនៅណុងដែរពូ?

ខៈ គាត់ធ្វើការងារដែរនឹង ចុះបើគាត់នៅទីនេះគាត់ធ្វើជាគ្រូបង្រៀន គាត់ធ្វើពេទ្យដែរនឹង គាត់ទៅទីនោះសុទ្ធតែអ្នកធ្វើការចឹងហាស

កៈ អូ៎!បាទពូចឹង ចុះបងមួយទៀត?

ខៈ ហើយបងទីពីររបស់ខ្ញុំគាត់មានឈ្មោះថា បងឌឿន គាត់ក៏ទៅនៅប្រទេសក្រៅដែរ ឈ្មោះបងឌឿននឹងជាបងទីពីរ ហើយបើបងទីបីឈ្មោះបងថានឹងគាត់នៅប្រទេសក្រៅដែរ

កៈ អូ៎!ម៉េចទៀតទៅពូ?

ខ៖  គាត់ទាំង3នាក់នឹងសុទ្ធតែស្រីនឹងគាត់សុទ្ធតែនៅប្រទេសក្រៅនឹង ទី1 ទី2 ទី3 នឹងនៅប្រទេសក្រៅ សំរាប់បងទី4គាត់មានឈ្មោះថាអ៊ឹម សុវណ្ណារិទ្ធិ

ក៖  ចុះគាត់នៅណាដែរពូ?

ខ៖  បង អ៊ឹម សុវណ្ណារិទ្ធិនឹងគាត់នៅភ្នំពេញទេ

ក៖  អូ៎!បងទី4នឹងនៅខ្មែរនឹងទេ?

ខ៖  នឹងហើយគាត់នៅភ្នំពេញនឹង ប៉ុន្តែគាត់អាឡូវនឹងគាត់អាត្រេតហើយ គាត់ចាស់ហើយ ហើយគាត់អាសាឈឺ ចឹងគាត់ឈប់ហើយនឹង នឹងបងទី4ប្រុស
សំរាប់បងទី5នឹងទៅនៅអាមេរិច

ក៖  អូ៎!ទី5ទៅនៅអាមេរិចវិញ?

ខ៖  នឹងហើយទី6 បានស្លាប់បាត់ទៅហើយនឹង ទី6នឹងប្អូនទេ
ហើយបងទី5នឹងនៅអាមេរិចបងនឹងខ្ញុំតែ2ឆ្នាំទេ ដល់ពេលទី6នឹងអាយុស្គរខ្ញុំនឹង គេស្លាប់នៅពេទ្យនៅរូស្ស៊ី

ក៖  គាត់ស្លាប់នឹងពេទ្យ?

ខ៖  បាទស្លាប់នៅពេទ្យ ដល់ពេលទី7ប្អូនរបស់ខ្ញុំឈ្មោះចាន់ រ័ត្ន ដល់ពេលដែរទី8ឈ្មោះ អ៊ឹម សុខធីតា ប្តីគេពីមុនគេហៅទីចន ហោស

ក៖  ទីចន នឹងនរណាគេដែរពូ?

ខ៖  ជាឯកឧត្តមទី ចន នោះ នឹងជាជីដូនមួយរបស់ខ្ញុំ ប៉ុន្តែជាប្តីរបស់គេទេណាស់
ដល់ពេលដែរទី9 នោះឈ្មោះ រ៉ស់ នៅនេះខ្ញុំហៅតែអារ៉ស់ៗៗ
ប៉ុន្តែដល់ពេលទៅនោះគេប្តូរឈ្មោះ មិនដឹងគេដាក់ឈ្មោះអីមិនដឹងទេណាស់

ក៖  អូ៎!ចឹងហោសពូ?

ខ៖  បាទ បើទី10មានប្អូនស្រីមួយដែរ ឈ្មោះ អ៊ឹមរ៉ា គេហៅវាថា អ៊ឹមរ៉ា នឹងទី10

ក៖  អូ៎!បាទពូ?

ខ៖  បើនិយាយពីប្អូនជីដូនមួយនឹងវារាប់ទៅប្អូនខ្ញុំសឹងតែ50ឆ្នាំដែរនឹង
វាក្បែរ50ឆ្នាំដែរនឹងហាស

ក៖  ចុះភរិយារបស់ពូមានឈ្មោះអីគេដែរពូ?

ខ៖ និយាយគ្រួសារខ្ញុំនឹង ឈ្មោះ សុភាព

ក៖ ចុះពូមានចងចាំថាពូបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅថ្ងៃខែឆ្នាំណាដែរទេពូ?

ខ៖ បើនិយាយអោយចំទៅគ្រួសាររបស់ខ្ញុំនឹងអត់បានចាំដែរនឹង

ក៖ ប៉ុន្តែដូចជាកូនរបស់ពូសព្វថ្ងៃនឹងគាត់អាយុប៉ុន្មានដែរហើយនឹង?

ខ៖ យើងបានកូនពៅពីព្រោះថាយើងចិត្តនឹងចិត្តទេ

ក៖ ម៉េចចឹងពូ?

ខ៖ ពីព្រោះថាចិត្តនឹងចិត្តគាត់ក៏មេម៉ាយ ខ្ញុំក៏មេម៉ាយដែរ

ក៖ អូ!ចឹងទេហោសពូ?
ខ៖ ប៉ុន្តែកូនពៅអាយុ16ឆ្នាំ

ក៖ ចឹងមានន័យថាប្រហែលជាពូការអស់រយះពេល17ឆ្នាំ ហើយណាពូ?

ខ៖ អត់ទេខ្ញុំការប្រហែលជាជិត20ឆ្នាំហើយនឹង និយាយពីកូនរាបផ្លូវឆ្ងាយចឹង ពីព្រោះយើងធ្វើការហាសណាស់

ក៖ បាទត្រូវហើយពូ?

ខ៖ ប៉ុន្តែកូនពៅរបស់ខ្ញុំនឹងគាត់អាយុ16ឆ្នាំ ប៉ុន្តែគាត់រៀនបានថ្នាក់ទី11 កូនស្រី

ក៖ ប៉ុន្តែពេលណុងដូនជាពូមានជំនូនអោយទៅអ៊ីស្រីខ្លះដែរទេ?

ខ៖ ជំនូនខំអត់មានទេ

ក៖ អូ!ចឹងទេហោសពូ?

ខ៖ គ្រាន់តែយើងស្រលាញ់ចិត្តហាសណាស់ ប៉ុន្តែមានមេប៉ា សែនព្រេនចឹងហាសណាស់ ទោះយើងមេម៉ាយក៏ដោយកុំអោយតែយើងអត់មេប៉ា ខ្លាចកាច់

ក៖ ចុះពូអាចប្រាប់ខ្ញុំបានទេថា ពេលណាដែរពូបានស្រលាញ់មីងពីដំបូងចឹង ហើយពូស្រលាញ់ពេលណា ហើយប៉ុន្មានឆ្នាំបានពូចូលស្តីមីងអីចឹងហាស?

ខ៖ អូ!កន្លងផុតបានមួយឆ្នាំជាងដែរទំរាំបាននិយាយគ្នាហើយ នេះគេហៅថាដូនថាយើងលេងសើចចឹងហាសណាស់

ក៖ យ៉ាងម៉េចវិញទៅពូ?

ខ៖ និយាយលេងសើចៗ ចេះតែនិយាយៗទៅ ហើយបានជិតមួយឆ្នាំដែរបាទ

ក៖ ចុះពូធ្លាប់បានរៀនទេ?

ខ៖ បាទខ្ញុំអត់បានរៀន និយាយអោយចំទៅខ្ញុំអត់បានរៀន បើនិយាយពីជំនាន់តាលុនណុល នឹងខ្ញុំបានរៀនដែរ

ក៖ បាទពូរៀនបានថ្នាក់ទីប៉ុន្មានដែរពូ?

ខ៖ ជំនាន់តាលុនណុលនឹងខ្ញុំរៀនបានថ្នាក់ទី1 ថ្នាក់ទី11ទេច្រឡំ

ក៖ អូ៎!រៀនបានថ្នាក់ទី11ហោសពូ?

ខ៖ ជំនាន់ណុង បើយើងនិយាយពីដើមនឹងយើងមិនមែនរៀនចាប់ពីថ្នាក់ទី11ណា

ក៖ និយាយពីថ្នាក់ទី12មកក្រោមមែនទេពូ?

ខ៖ នឹងហើយ គេរាប់ពីលើចុះមកហាសណាស់ ដល់ពេលដែរខ្ញុំប្រលងជាប់ថ្នាក់ទី10ចឹងទៅគាត់បានបែកហើយនឹងហាស

ក៖ អូ៎!ចឹងហោសពូ?

ខ៖ នឹងហើយកាលណុងយើងបែកហើយ ក៏ចូលសង្គ្រាម់ជំនាន់ឆ្នាំ1975ហាសណាស់

ក៖ ចុះពេលណុងពូរៀននៅណាដែរ?

ខ៖ ខ្ញុំរៀននៅជ្រោយចង្វារនឹង

ក៖ នៅជិតជ្រោយចង្វារ

ខ៖ នៅជិតដព្ធកំពង់ដ អរិយក្សត្រ មិនមែនទេ នៅកំពង់ដ អារិច

ក៖ នៅកំពង់ដ អារិចណោះពូ?

ខ៖ ដែរលឺគេហៅថា កំពង់ដ អារិចទេ?

ក៖ អត់ដែរលឺទេពូ

ខ៖ កំពង់ដ អារិច នឹងបើនិយាយទៅមិនមែននៅចំស្ពាន់ជ្រោយចង្វារតែម្តងទេណាស់ នៅឆ្លងស្ពានមួទៀតទេណាស់

ក៖ ចឹងមិនមែននៅជាប់ស្ពានជ្រោយចង្វារទេ?

ខ៖ នឹងហើយខ្ញុំទៅឆ្លងទន្លេមួយទៀត

កៈ  អូ៎!ចឹងនៅស្ថានមួយទៀត?

ខៈ  នឹងហើយខ្ញុំទៅរៀនគេហៅកំពង់ដ អារិចនឹង ខ្ញុំទៅរៀននៅកំពង់ដ អារិចនឹងឆ្ងាយណាស់ដើរទៅរៀន នឹងបងប្អូនរបស់ខ្ញុំនឹង ហើយម្តាយគាត់ជាកម្មករតោន

កៈ  អូ៎!ម្តាយរបស់ពូ?

ខៈ  គាត់លីអង្ករ ចេញពីផែកប៉ាល់ យកមកលើចឹងទៅនឹងម្តាយរបស់ខ្ញុំនឹងហាស

កៈ  អូ៎!គាត់ពិបាកដែរចឹង?

ខៈ  គាត់ពិបាក ចឹងគាត់ក៏ដាស់អោយខ្ញុំមករៀនៗពីព្រោះសាលាខ្ញុំឆ្ងាយ ខ្ញុំដើរចឹងជាង5-6គីឡូដីចឹងទៅ

កៈ  ចុះពូមានមិត្តភក្តិស្និទ្ធស្នាលអត់?

ខៈ  កាលពីជំនាន់ណុងខ្ញុំមិនសូវចេះរាប់អានមិត្តទេ

កៈ  អត់មានមិត្តទេពូ?

ខៈ  និយាយរួមទៅកាលណុងខ្ញុំនៅតូច និយាយអោយចំទៅខ្ញុំទៅរៀនដឹងតែទៅរៀន

កៈ  ហើយក៏មកផ្ទះវិញដែរទៅ?

ខៈ  បើមិត្តភក្តិវិញអោយនិយាយលេង និយាយលេងប៉ុន្តែអោយស្និទ្ធស្នាលវិញដូចជាអត់មានទេ លក្ខណះថាអោយយើងស្រលាញ់ចិត្តមួយថ្លើមមួយចឹងហាស

កៈ  អូ៎!បាទពូ?

ខៈ  កាលពីនៅតូចៗ ប៉ុន្តែឥឡូវនឹងក៏ចឹងដែរនឹង អោយរាប់អានមិត្តភក្តិចឹង ក៏រាប់អានទៅ បើអោយស្រលាញ់រាប់អានអី ពីចិត្តមួយថ្លើមមួយចឹងដូនជាមិនសូវមានទេ

កៈ  បាទចឹងពូ ចុះពូធ្លាប់ទៅធ្វើការងារនៅវាលស្រែទេពូ?

ខៈ  បាទវាលស្រែខ្ញុំមិនដែរធ្វើទេ

កៈ  លក្ខណះថាស្រែចំការហាសពូមិនដែរទេណាពូ?

ខៈ  បាទអត់ដែរទេ ពីព្រោះអីថា ខ្ញុំកើតមកម្តាយរបស់ខ្ញុំនឹងនៅភ្នំពេញ តាំងពីខ្ញុំចេះដឹងក្តីមកខ្ញុំនៅភ្នំពេញរហូតនឹង

កៈ  ចឹងមានន័យថាពូនៅភ្នំពេញរហូតនឹង?

ខ៖ បើនិយាយអោយចំទៅវាមិនអត់ទេ កាលពីជំនាន់ពលពតនឹង
ខ្ញុំក៏ធ្លាប់ទៅធ្វើស្រែជាមួយគេដែរនឹង ប៉ុន្តែមិនមែនជាអាជីពយើងហាស

ក៖ លក្ខណះថាអចិន្ត្រៃហោសពូ?

ខ៖ បាទនឹង ក្រៅពីនឹងមិនដែរទេ
គ្រាន់តែថានិងគ្រាន់តែជាការជំលាសទៅជំនាន់ពលពតហាស
បើយើងមិនជួយអាពតទុកអោយយើងស្លាប់

ក៖ បាទត្រូវហើយពូ បើយើងមិនធ្វើទេពិបាកដែរ?

ខ៖ បានអោយគេយកទៅវៃចោលហី

ក៖ ចុះពូមានធ្លាប់បើកអាជីវកម្មលក់ដូរអីទេ?

ខ៖ បាទខ្ញុំអត់ដែរផងនឹង

ក៖ ប៉ុន្តែប្រពន្ធរបស់ពូសព្វថ្ងៃលក់?

ខ៖ បាទលក់ពោតនឹង អានឹងដូចថាជាមុខរបរគេរកស៊ីពោតស្ងោរ
សំរាប់ខ្ញុំដឹងតែជាជាងធ្វើទ្វា បង្អួច នឹងជាជាងកំប៉ោ

ក៖ បាទពូ ចុះពូធ្លាប់ចិញ្ចឹមសត្វទេ?

ខ៖ បាទខ្ញុំចូលចិត្ត ពីព្រោះមិនដែរថាទៅរៀនពីនរណាទេ
ប៉ុន្តែខ្ញុំចូលចិត្តចិញ្ចឹមសត្វតែម្តងនឹង

ក៖ អូ៎!ពូចូលចិត្តចិញ្ចឹមសត្វ?

ខ៖ ហើយកសិកម្មដាំបន្លែ អីនឹងដូចថា មិនបាច់រៀនក៏ខ្ញុំចេះដែរនឹង

ក៖ អូ៎! បាទពូ ចុះការងារអីគេខ្លះដែរពូធ្លាប់ធ្វើតាំងពីក្មេងរហូតមកដល់ពេលនេះ?

ខ៖ បើនិយាយពីការងារដែរខ្ញុំធ្វើនិងគឺធ្វើជាជាងឈើនឹង

ក៖ ពូធ្វើជាជាងឈើ?

ខ៖ នឹងហើយជាជាង ទ្វាបង្អួច នឹងជាជាងកំប៉ោ

ក៖ អូ៎!បាទពូ
ចុះពូគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះពូគិតថាជីវិតរបស់ពូមានការផ្លាស់ប្តូរអីគេខ្លះ
ដែរទៅពូ?

ខ៖ ដូចជាអត់មានការផ្លាស់ប្តូរទៅណាផងពីព្រោះ ខ្ញុំទៅតែរកនឹងតាំងពីខ្ញុំដឹងក្តីមកនឹង បើនិយាយពេញវ័យនឹងខ្ញុំធ្វើជាកម្មករសំណង់

ក៖ អូ៎!ពូធ្វើជាកម្មករសំណង់?

ខ៖ នឹងហើយធ្វើរហូតដល់ខ្ញុំទៅជាមេជាងចឹងហាស

ក៖ អូ៎!បាទពូ ចុះម្ហូបអីដែរពូចូលចិត្តពិសារដែរនឹង?

ខ៖ បើនិយាយអោយចំទៅម្ហូបស្លស្ទីក៏ខ្ញុំមិនប្រកាន់ដែរ

ក៖ ចឹងហោសពូ?

ខ៖ បាទប៉ុន្តែ ពេលព្រឹកម្ហូបផ្សេង ហើយពេលដែរល្ងាចម្ហូបផ្សេងទៅ កុំអោយតែព្រឹកក៏អានឹង ហើយល្ងាចក៏អានឹងដែរ

ក៖ បាទត្រូវពូ?

ខ៖ ខ្ញុំមិនដែរប្រកាន់ទេនឹង

ក៖ ចុះពូតាំងពីក្មេង តើពូចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេដែរ ដូចជាបោះអង្គុញ ចោលឈូង លាក់កន្សែង ទាញព្រាតអីចឹង?

ខ៖ បើនិយាយពីចំណូលចិត្តរបស់ខ្ញុំនឹង ខ្ញុំចូលចិត្តលឹងអ៊ូ

ក៖ អូ៎!ចូលចិត្តលេងអ៊ូណាពូ?

ខ៖ ក្មួយដែរលេង នឹងស្គាល់ទេ?

ក៖ បាទពូ ស្គាល់ ហើយដែរលឹងដែរពូ

ខ៖ បាទមួយនឹង

ក៖ ខ្ញុំធ្លាប់លេងដែរនឹង?

ខ៖ ខ្ញុំចូលចិត្តលេងអ៊ូនឹង

ក៖ លេងអ៊ូសប្បាយដែរតាពូ?

ខ៖ បើចឹងទេ លេងបោកចំបាប់ក៏ខ្ញុំចូលចិត្តលេងដែរ

ក៖ អូ៎! បោកចំបាប់ហោសពូ?

ខ៖ បោកចំបាប់កាលពីនៅជំនាន់ពលពតគេចាប់គូរអោយបោកតា

កៈ  អូ៎! មានមួយនឹងដែរកាលពីជំនាន់ណុង?

ខៈ  នឹងហើយមិនមែនទេបង្ខំយើងទេ ប៉ុន្តែគេសួរយើងហ៊ានទេ
វាចង់ដឹងថាមាននរណាគេខ្លាំងរឺមិនខ្លាំងចឹងហាសណាស់

កៈ  អូ៎!មានអីល្អតាពូ?

ខៈ  ខ្ញុំលេងបោកចំបាប់ចឹងទៅ

កៈ  ចុះបូចេះច្រៀងទេ?

ខៈ  និយាយពីច្រៀងអោយចំទៅមិនមែនថាមិនចេះទេ ប៉ុន្តែលក្ខណះថា
បានមួយបទពីរបីម៉ាត់ចឹងទៅ មិនមែនថាមិនចេះទេកាលពីក្មេងនឹងខ្ញុំចូលទៅ
គេទៅលេងភ្លេង ហើយគេអោយជាអ្នកចំរៀង

កៈ  គេអោយពូច្រៀង?

ខៈ  គេអោយខ្ញុំជាអ្នកចំរៀងដែរ ប៉ុន្តែខ្ញុំនឹកឃើញថាអោយខ្ញុំជាអ្នកចំរៀង
ប៉ុន្តែអោយខ្ញុំម៉េចបើអត់ចេះអក្សរផង អោយខ្ញុំជាអ្នកចំរៀងម៉េចកើត

កៈ  អូ៎!ពេលណុងពូមិនចេះអក្សរទេ?

ខៈ  នឹងហើយប៉ុន្តែខ្ញុំចង់លេងភ្លេងហាសណាស់

កៈ  ចង់លេងភ្លេងវិញហោសពូ?

ខៈ  បាទខ្ញុំចង់លេងភ្លេង ឥឡូវនឹងខ្ញុំសុំគ្រូភ្លេងនឹង កាន់ប៉ាស់
ប៉ុន្តែគ្រូប្រាប់ថាមិនបានទេអោយខ្ញុំច្រៀងពិរោះជានឹង

កៈ  អូ៎!ម៉េចចឹងពូ?

ខៈ  អោយខ្ញុំច្រៀងប៉ុន្តែខ្ញុំនឹកឃើញថាខ្ញុំមិនចេះអក្សរទេ ហើយតែច្រៀងនឹងវាពិបាក
ហើយយ៉ាងណាមួយទៀតនឹង ម្តាយរបស់ខ្ញុំគាត់ប្រាប់ថាបើឯងចេះលេងភ្លេងនឹង
ប្រពន្ធនឹងច្បាស់ជាអត់អង្ករច្រកហើយនឹង

កៈ  ម៉េចចឹងពូ?

ខៈ  នឹងវាចឹងកាលពីជំនាន់ចាស់គេនិយាយចឹង

កៈ  ចឹងហោសពូ?

ខ៖ ខ្ញុំក៏តាមគាត់ទៅ ខ្ញុំនឹកឃើញថាម្តាយចាអ្នកមានគុណចឹង គាត់ប្រាប់ទៅបើយើងមិនតាថាយើងនឹងចង់ឈ្នះគាត់

ក៖ បាទត្រូវហើយពូ

ខ៖ បានជាខ្ញុំឈប់លេងភ្លេងទៅ កាលណុងគេអោយខ្ញុំជាអ្នកចំរៀង គេអោយខ្ញុំជាអ្នកចំរៀងនឹងនៅក្នុងជំនាន់ឆ្នាំ1983

ក៖ បាទពូ! ចុះពូមាននរណាគេម្នាក់នៅក្នុងក្រុមគ្រួសាររបស់ពូ ដែរចេះលេងឧបករណ៍ភ្លេងដែរទេពូ?

ខ៖ អត់មានផងនឹង

ក៖ ចឹងអត់មានទេណាពូ?

ខ៖ បាទមិនដែរមានទេ

ក៖ ចុះផ្ទះរបស់ពូមានលក្ខណះបែបណាដែរពូ តាំងពីក្មេងរហូតមកដល់ពេលនេះ មានលក្ខណះបែបនាដែរទៅ

ខ៖ ខ្ញុំសព្វថ្ងៃនឹងនៅផ្ទះជួលគេ

ក៖ ពូជួលគេណាពូ ប៉ុន្តែកាលពីនៅក្មេងនឹងផ្ទះរបស់ពូនឹងយ៉ាងម៉េចដែរពូ?

ខ៖ បើនិយាយទៅផ្ទះនៅក្មេង រស់នៅជាមួយម្តាយរបស់ខ្ញុំនឹង ប្រកជាស័ង្កសី ប៉ុន្តែជញ្ជាំងយើងនឹងប្រកស្លឹកនឹងធម្មតា

ក៖ បាទពូ ចុះដូចជានរណាគេជាអ្នកសាងសងផ្ទះរបស់ពូដែរ?

ខ៖ បាទខ្ញុំជាអ្នកសាងសងតែម្តងនឹង

ក៖ អូ៎!ពូចេះធ្វើផ្ទះណាពូ?

ខ៖ បាទ ផ្ទះក៏ខ្ញុំចេះធ្វើ ជាជាងស្មីក៏ខ្ញុំចេះធ្វើ ជាងសំប៉ោ ក៏ខ្ញុំចេះធ្វើ គ្រាន់តែថាធ្វើមិនមែនជាលក្ខណះធំដុំទេណាស់

ក៖ អូ៎!ចឹងហោសពូ?

ខ៖ បើអោយខ្ញុំទៅម៉ៅគេរាប់ពាន់អីបាន តែប់អោយរាបម៉ឺនវិញយើងអត់មានលុយស្លួលទេ

ក៖ បាទចឹងពូចេះធ្វើតូចៗ?

ខ៖  បើអោយម៉ៅនឹង អាចម៉ៅបានប៉ុន្តែខ្លាចតែវាខាតទៅ វាគ្មានអីសងគេ ពីព្រោះយើងវាគ្មានលុយសងគេនឹង និងនិយាយអោយចំទៅ

ក៖  ចុះពូគិតថាជំនាញអីដែរពូចេះស្ទាត់ជំនានដែរពូ?

ខ៖  បាទស្ទាត់ជំនាញជាងគេមានតែជាងកំប៉ោ ជាងឈើ ជាងផ្ទះនឹង

ក៖  នឹងពូចេះធ្វើស្ទាត់តែម្តងហោសពូ?

ខ៖  បាទចេះស្ទាត់ ផ្ទះឈើក៏អាចធ្វើបាន ផ្ទះថ្មក៏ខ្ញុំចេះដែរ

ក៖  ចុះឪពុកម្តាយរបស់ពូគាត់មានធ្លាប់បង្រៀនពីជំនាន់អីផ្សេងទៅពូដែរទេ ដូចជាលក្ខណះថាកូរស្គ វេញវល្លិ៍?

ខ៖  អត់ទេអានឹងគ្មាននរណាគេប្រាប់ខ្ញុំផងនឹង ដូចដុងខ្លួនឯងចេះខ្លួនឯងតែម្តងនឹងហាស

ក៖  អូ៎!ឡូយពូ?

ខ៖  ខ្ញុំទៅរៀនលួចមើលគេចឹងទៅខ្ញុំចេះ

ក៖  ចុះពូអាចប្រាប់បានទេថា ពេលណាដែរពូគិតថាជាពេលដែរលំបាកនៅក្នុងជីវិតរបស់ពូហាស?

ខ៖  និយាយពីកាលលំបាកនឹងវេទនាណាស់មួយថ្ងៃកាត់ មួយថ្ងៃកោ បើខ្ញុំពិការចឹង ខ្ញុំអាចរកអីបានហោស ចង់និយាយថាយើងធ្វើបានតែការងារណាដែរស្រាលៗទេ

ក៖  អូ៎!ចឹងហោសពូ?

ខ៖  ខ្ញុំធ្វើជាកម្មករចឹងទៅដូចថាកន្លែងណាដែរត្រូវឡើងចឹងទៅខ្ញុំមិនហ៊ានឡើងទៅ មកពីយើងវាអន់ភ្នែកចឹងហាស

ក៖  បាទពូត្រូវហើយ

ខ៖  បាទដល់ពេលដែរវាអន់ភ្នែកចឹងដល់ពេលចឹងខ្ញុំម៉េចហ៊ានឡើង ហើយយ៉ាងណាមួយខ្លាចតែថ្ងៃណា រឺម៉ោងណាមួយដែរសុខភាពមិនសូវល្អចឹងហាស

ក៖  បាទត្រូវហើយពូត្រូវ

ខ៖  ដល់ពេលចឹងហើយមានល្មមៗមិនហ៊ានឡើងទេនឹង

ក៖  ចឹងបានតែការងារស្រាលៗទេ?

ខ៖  នឹងហើយ បានតែការងារទាបៗនោះទេ

កៈ  អូ៎!ចុះពូឆ្លងកាត់ឧបសគ្គមួយនឹងដោយរបៀបណាដែរពូ?
ខៈ  ពិបាកដែរអារឿងការឆ្លងកាត់នឹង វាពិបាកអារឿងធ្វើការងារសំណង់នឹងវាមិនងាយទេ ធ្វើកម្មករគេ ដូចកម្មករវៀតណាមនេះមួយ វាជេ យើងចេះតែទ្រាំៗទៅ ហេតុតែយើងចង់ចេះហាសណាស់

កៈ  បាទត្រូវហើយពូ?

ខៈ  មកពីយើងមិនមានដើមទុនចឹងយើងចង់ចេះចេះតែតស៊ូនឹងគេទៅ

កៈ  មានតែចឹងទេបានយើងចេះ?

ខៈ  គេជេយ៉ាងម៉េចក៏ឆ្អែតដែរនឹងហាស ចុះយើងមិនចេះភាសាគេ ចឹងគេជេយ៉ាងម៉េចក៏ជេទៅ

កៈ  យើងអត់ខ្វល់ទេ?

ខៈ  នឹងហើយយើងមិនខ្វល់ទេ

កៈ  អូ៎!ចឹងហោសពូ?

ខៈ  វៀតណាមចង់ជេខ្ញុំយ៉ាងម៉េចក៏ជេទៅបើខ្ញុំវាមិនចេះផង បើចង់ជេយ៉ាងម៉េចក៏ជេទៅបើអញ់អត់ដឹងផងនឹង

កៈ
ចុះពូគិតថាពេលណាដែរពូគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់ពូដែរ?

ខៈ  ខ្ញុំគ្មានថ្ងៃសប្បាយទេក្មួយអើយ ថ្ងៃណាក៏គ្មានថ្ងៃសប្បាយដែរក្មួយ

កៈ  អូ៎!ចឹងហោសពូ?

ខៈ  ចិញ្ចឹមកូនហើយ ឥឡូវនឹងចិញ្ចឹមដល់ទាំងចៅទៅទៀតនឹង គ្មានអីសប្បាយទេគិតមើលទៅតិចៗៗដល់ខែផ្ទះទឹកភ្លើងៗៗគ្រាន់តែផ្ទះមួយខែ50$

កៈ  អូ៎! ផ្ទះ50$ហោសពូ?

ខៈ  គ្រាន់តែទឹកក៏ថ្លៃ ហើយភ្លើង ក៏ថ្លៃ គ្រាន់តែភ្លើងមួយខែនឹងវាអស់ជិត70000រៀល

កៈ  អូ៎!ថ្លៃដែរនឹងហាស?

ខៈ  នឹងហើយនៅទឹកទៀត នឹងនិយាយទៅក្បែរនឹង100$ដែរនឹងហាស

កៈ បាទពូ ចុះពូកិតថាតាំងពីក្មេងពូគិតថាធ្លាប់មានក្ដីស្រម៉ៃដែរទេ ថាពេលដែរពូធំឡើងពូចង់ធ្វើអីគេដែរចឹងហាស?

ខៈ បាទតាំងពីក្មេងចង់ស្រម៉ៃ ហើយណាស់ ខ្ញុំស្រម៉ៃថាពេលដែរខ្ញុំធំឡើងចង់ស្រម៉ៃថាចង់បើកឡានដូចប៉ារបស់ខ្ញុំចឹងហាសណាស់ នឹងហើយបើកឡានចឹងទៅស្រណុក ហើយយើងបើកឡានចឹងទៅវាស្រណុក ប៉ុន្តែយើងមិនបានដូចបំណងចឹងហាស

កៈ អូ៎!ពូមិនបានសម្រេចក្ដីបំណងណាពូ?

ខៈ នឹងហើយគ្រាន់តែថាវាមិនបានស្រណុកដូចក្ដីស្រម៉ៃចឹងហាស

កៈ ចុះបើចង់អោយពូផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗតើពូចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរពូ?

ខៈ បាទខ្ញុំគ្រាន់តែចង់អោយកូនចៅជំនាន់ក្រោយៗខំប្រឹងទៅ ហើយធ្វើការងាររៀនសូត្រទៅណាស់ បាទខំយកចំនេះវិជ្ជា កុំដើរប្រព្រឹត្តរឿងគ្រឿងញៀន វាគ្មានប្រយោជន៍ទេ

កៈ បាទត្រូវហើយពូ?

ខៈ ពីព្រោះកូនចៅរបស់ខ្ញុំនេះអាយុ16ឆ្នាំវារៀនថ្នាក់ទី11

កៈ រៀននៅណាដែរពូ?

ខៈ រៀននៅបឹងត្របែកយើងនេះនឹងកូនស្រីទេ ខំអោយវារៀនចេះដើម្បីអោយវាយកចំនេះវិជ្ជាទៅណាស់ ហើយឪគ្មានផ្ទះដូចគេទេ ខំអោយវារៀនចេះទៅដើម្បីយកចេះនេះទៅ សង្ឃឹមឪពុកម្ដាយមិនដឹងពេលណាទៀតទេ យើងអាយុប៉ុណ្ណឹងៗហើយនឹងមែនទេ?

កៈ បាទត្រូវហើយពូ

ខៈ នឹងហើយវាកាន់តែទៅមុខហើយមួយឆ្នាំកាន់តែទៅបន្តិចៗហើយណាស់

កៈ អូ៎!លក្ខណៈថាវារៀងជ្រេលទៅមុខមែនទេពូ?

ខៈ នឹងហើយកាន់តែទៅមុខនឹង មួយឆ្នាំទៅបន្តិចៗដូចលក្ខណៈថាយើងដាំដើមចេកហាសណាស់

កៈ បាទពូត្រូវហើយ

ខ៖ បាទខ្ញុំសូមអោយកូនក្មួយទាំងអស់គ្នា ខំប្រឹងរៀនសូត្រ ហើយជៀសវាងពីគ្រឿងញៀនទៅកុំអោយប្រព្រឹត្តពីព្រោះសង្គមកំពុងតែស្អប់ហើយយើងទៅប្រព្រឹត្តអីទៀតនឹង

ក៖ បាទចុះមានអីចង់ផ្ដែផ្ដាំអីផ្សេងទៀតទេពូ?

ខ៖ បាទខ្ញុំដូចជាមិនមានរឿងអីគ្រាន់តែថាផ្ដាំកូនចៅ
កុំអោយប្រព្រឹត្តជំនាន់នេះមានគ្រឿងញៀនអីចឹងហាស
កុំអោយដើរធ្វើអំពើដើរឆក់ប្លន់បងប្អូនទូទៅ
ខំប្រឹងរៀនសូត្រយកអនាគត់យើងកំពង់តែត្រូវការចឹងហាស

ក៖ បាទពូ!
ចឹងខ្ញុំអរគុណច្រើនពូដែរបានផ្ដល់ពេលវេលាដែរបានពិភាក្សាជាមួយខ្ញុំដែរទាក់ទងទៅនឹងប្រវត្តិរបស់ពូ ចឹងអរគុណច្រើនចឹងហាសពូ

ខ៖ បាទៗៗក្មួយ!!!!

ក៖ បាទចឹងអរគុណណាស់ពូ៕៕៕